## EXECUTIVE SUMMARY

In order to contribute to the promotion of fundamental freedoms with the support from the United Nations Democracy Fund (UNDEF), "Strengthening Local Capacity to Improve Policies in Cambodia" project has implemented its activities in 252, villages, 35 commune, 18 districts of 8 target provinces: Siem Reap, Kampong Cham, Preah Vihear, Ratanakiri, Banteay Meanchey, Battambang, Mondulkiri and Kampong Chhnang provinces, covering key activities such as: conducting training courses on fundamental freedoms, advocacy and networking, meetings with commune / sangkat and provincial authorities, organizing regional and national workshops.

Through the implementation of a series of activities including the national workshop, the project has uncovered some of the following findings to submit to the relevant ministries and institutions to explore specific, peaceful and harmonious solutions for the people in the community:

- Communities' 17 challenges related to fundamental freedoms, 14 responses from the sub-national authorities, and 26 suggestions (recommendations) from the communities.
- H.E. Katta On of the Cambodian Human Rights Committee (CHRC) has promised to raise the 17 challenges and the 26 recommendations (suggestions) in the agenda of the Inter-Ministerial Meeting of the Cambodian Human Rights Committee, which consists of 20 relevant ministries. In particular, His Excellency will organize a meeting with the six relevant ministries to explore the possibility of resolving those challenges for the people. The six relevant ministries/institutions are: Ministry of Interior, Ministry of Justice, Ministry of Land Management, Urban Planning and Construction, Ministry of Environment, Ministry of Agriculture (Forestry Administration) and Apsara Authority.
- Representatives of both civil society organizations, LICADHO's General Manager, and the Executive Director of the Cambodian Center for Human Rights, fully agreed with the findings, challenges and recommendations regarding ADHOC's fundamental freedoms.
- Request the Cambodian Human Rights Committee to help remove some content in the White Book produced by the Office of the Council of Ministers, which implicates some civil society organizations with color revolution… This has triggered local authorities to

tighten and monitor all activities of the organizations, especially those listed in the White Book.

- By participating in debate activities from the commune/sangkat to the provincial levels, local authorities seem to have already recognized their actions upon the uncovering of the 17 community challenges, said ADHOC's Director.

*More information:*

1. Mr. Meas Savath, Secretary General of ADHOC, 086 385 666
2. Mr. Soeung Sen Karuna, Spokesman and Duputy Director in charge of Human Rights and Land Rights, 086 324 666

REPORT

## 1. Introduction

ADHOC is the first Cambodian human rights association founded on December 10, 1991 for advocating human rights and democracy, was officially recognized and approved by Samdech Preah Norodom Sihanouk on March 10, 1992, and was officially recognized by the Ministry of Interior, through Prakas No. 278, dated March 28, 2000. ADHOC has been carrying out key activities such as local community empowerment, advocacy and monitoring and interventions related to abuses of human rights, land rights, and the rights of women and children.

"Strengthening Local Capacity to Improve Policies in Cambodia" project aims to promote the rights of local communities to participate in public debates through the development and enhancement of knowledge of human rights, fundamental freedoms, networking, advocacy skills and the ability to get their voices heard in order to restore a culture of dialogue between local communities and sub-national and national government agencies and to contribute to policy improvements to ensure the promotion of democracy and respect for human rights in Cambodia.

## 2. Project overview



**Root causes**: In recent years, after the 2013 national election, the decline in respect for human rights and fundamental freedoms has been seen as having profound effects on democratic process, sustainable development and poverty reduction. Freedom House's 2019 Freedom Report ranks Cambodia as a "non-free country" and the country lost four points between 2017 and 2018, marking one of the most significant declines in the world

Restrictions on civil society and fundamental freedoms are hindering Cambodia's progress, especially among poor communities and people with disabilities living in remote areas who possess little knowledge of their fundamental rights and freedoms, thus disabling them from getting involved in democratic development and they become very vulnerable to human rights abuses. These factors are at odds with United Nations Sustainable Development Goals (SDG)'s **Target 16.7:** "Ensure responsive, inclusive, participatory and representative decision-making at all levels."; **Target 16.10**: "ensure public access to information and protect fundamental freedoms, in accordance with national legislation and international agreements"; **Goal 1**: End poverty in all its forms everywhere"; **Goal 5**: "Achieve gender equality and empower all women and girls; and ADHOC has identified the following three key problems:

- **Problem 1**: Lack of skilled knowledge of advocacy and local community networking
- **Problem 2**: Communication - provision and reception of information remains unclear among local communities to express their concerns and challenges and give recommendations to local, provincial and national authorities.
- **Problem 3**: Space for culture of dialogue between local community members to share their concerns, challenges and recommendations with national and local authorities is still limited.

To participate in the development and promotion of democracy, especially fundamental freedoms, with funding support from the United Nations Democracy Fund (UNDEF), Adhoc has implemented its activities in 252, villages, 35 commune, 18 districts of 8 target provinces: Siem Reap, Kampong Cham, Preah Vihear, Ratanakiri, Banteay Meanchey, Battambang, Mondulkiri and Kampong Chhnang provinces, covering 06 key activities such as: conducting training courses on fundamental freedoms, advocacy and networking for 1,225 community representatives from 35 communes/sangkats; meetings with local authorities, with main focuses on fundamental freedoms; meetings with provincial authorities, discussing communities' challenges and recommendations which have not been clearly addressed; regional workshops which continued to discuss with the communities about the challenges, recommendations, and unclear solutions from the provincial authorities in order to design

strategic plans and collect inputs for further discussion at the national workshop; and update meeting with national authorities in order to continue the discussion of the national workshop's report.




**128 meetings among community representatives** and local authorities within 35 communes/sangkats of 8 target provinces. These meetings presented opportunities for the community to raise various issues happening within their communities, especially to directly raise their concerns, challenges, recommendations to the local authorities to explore specific solutions. These meetings were attended by a total of 2,052 participants which included 1,028 community representatives (600 were women, 383 young adults, and 559 members of indigenous people), 495 commune/sangkat councilors, and 274 officers of administrative police posts.

According to the analysis, only 15% of the issues raised by the community were responded, while the remaining issues and recommendations were prepared for further discussion at the provincial level.



Preaek Koy Commune, Kang Meas district, Kampong Cham Province (at Preaek Koy Commune's Office)




**<u>06 meetings with provincial authorities</u>** of the 8 target provinces. These meetings allowed community representatives to raise issues which had not yet been resolved during their meetings with local authorities for further discussions to find the solutions. These meetings were attended by 86 community representatives, 41 deputy provincial governors, deputy provincial police chiefs, provincial military police, and officials from the concerned provincial departments, and 31 commune/sangkat councilors and officers of the administrative police posts.

According to the analysis, only 20% of the issues were responded, while the remaining issues and recommendations were updated for further discussion at regional workshops before being discussed at the national level.

**According to the report**, reasons that led to failure in organizing meetings with two provinces include:

- **Preah Vihear province**: The provincial governing board lacks cooperation, trying not to coordinate these meetings to happen, even if ADHOC, through its letters, had tried to seek for their cooperation and invite them to the meetings. For more than two weeks, the provincial administration did not respond to our letters and repeated phone calls and we did not see them at their offices on many occasions of our attempts to see them.
- Battambang province: Because the provincial governing board and many officials were so busy with improving the party performance ahead of the commune/sangkat elections that they could not have time to have the meetings.



Photo: A meeting with Kampong Cham provincial authorities

**Regional workshops**

**2 regions = 127 Pax**




**<u>02 regional workshops</u>** were attended by 127 representatives of 35 local communities of 8 target provinces. The first workshop was held in Kampong Cham province with 65 participants (including representatives from the United Nations) from 4 provinces: Ratanakiri, Kampong Cham, Mondulkiri and Siem Reap, and the second workshop was held in Banteay Meanchey, with a total of 62 participants from 4 provinces: Kampong Chhnang, Battambang, Preah Vihear and Banteay Meanchey.

These workshops provided an opportunity for local community representatives to share with other participants their concerns and challenges related to their fundamental freedoms and the opportunity for them to work together to provide recommendations to the government on continuing to explore solutions for their challenges and to develop strategic advocacy plans for the national workshop.



**Battambang Provinces**

**Challenges**

1. The authorities required the community to submit a notice or make a call notification. When the community had any meeting, the police took their pictures and checked documents.
2. The authorities regarded them as opposition groups if they criticized public services, political issues, or corruption

Recommendations (Resolutions):

1. The authorities should listen to criticisms and take them into consideration and avoid regarding them as opposition groups.
2. Public forums should not limit topics. People should be permitted to voice their concerns.



From the 128 meetings at the local level, 06 meetings at the provincial level and 02 regional workshops, inputs were collected and consolidated for the national workshop which was attended by concerned ministries, in particular, the Ministry of Interior and Ministry of Justice, to explore the solutions. The inputs collected after the sub-national authorities failed to locate the solutions include: the challenges and recommendations of the local communities and the action plans developed by the communities which sought for changes and approval from the government:

01 National Workshop: It was a two-day (23-24 August, 2022) workshop at Sunway Hotel, with a total number of 143 participants (49 women), which included 113 community representatives, 24 civil society organizations' staff members, 05 social media journalists, and 01 representative from the Cambodia Human Rights Committee (representatives from the Ministry of Interior and Ministry of Justice were absent).






These workshops achieved remarkable results: 17 community challenges, 14 sub-national authority responses and 26 community suggestions (recommendations), and the representative of the Human Rights Committee made a promise to include these findings in the agenda of discussions among the human rights technical group which is composed of 20 inter-ministerial representatives to find solutions for the communities. Meanwhile, the representative of the Cambodian Center for Human Rights and the Cambodian League for the Promotion and Defense of Human Rights, LICADHO, fully agreed with ADHOC’s findings, while the President of ADHOC stressed that by participating in local and provincial meetings, the authorities have acknowledged the challenges and suggestions (recommendations) raised by the local communities and have made responses to certain challenges.

**General issues**: Those issues are related to infrastructure and access roads in the communities, health and sanitation, security and safety in the villages and communes, migration, illegal fishing, land disputes involving powerful and wealthy elites, illegal encroachment of protected forests, closure of Trapaing Thmor reservoir which affected the

farming activities of the nearby farmers, domestic violence, declining livelihoods, poverty and inability to pay loans.

## Challenges related to fundamental freedoms: (17)

1. Some local authorities were constantly watching, monitoring, asking questions and requiring the communities to report them after attending the meetings or workshops with civil society organizations.
2. Authorities threatened people with imprisonment warning! If people attended a meeting or a course with an organization, they must report to the authorities when attending a meeting related to filing a land dispute complaint.
3. Some local authorities considered any community which dared to give constructive criticisms on public service delivery inactivity or dared to talk about corruption as an opposition group.
4. Local authorities restricted communities from speaking or complaining about land disputes or forest issues.
5. The authorities prevented the communities from filing petitions with the provincial administrations or the ministries.
6. The authorities failed to maintain the confidentiality of the communities' members when they reported about various crimes, putting their personal security and safety at risk, so they no longer dared to report any further.
7. Political expression was restricted and intimidated by the authorities.
8. Authorities did not provide opportunities for dissidents to participate.
9. Commune councils have not yet cooperated in allowing communities to attend their monthly meetings.
10. Authorities restricted and discriminated against communities in engaging with civil society and political activities (eg: surveillance, interrogation, taking pictures, intimidation) by accusing and painting them with political party tendencies.
11. Village authorities restricted youth participation in various social activities, such as road repairs, sharing knowledge about the rights and roles of citizens.

12. The authorities restricted the meetings of civil society organizations and communities at the local level and required prior notice and permission, demanded certified documents, took pictures, listened to the meeting, and required our reports on locations by sending them pictures of the activities.
13. Members of the communities were afraid to post messages about their political opinions.
14. The Apsara Authority did not provide an appropriate solution to the request of the community regarding their housing rights.
15. The commune authorities threatened and brought the representatives for questioning after they raised land disputes in the meeting.
16. Environment officials in such provinces as Preah Vihear, Mondulkiri, Ratanakiri and Siem Reap did not allow communities to participate in monitoring and protecting public property.
17. When the communities saw and reported forest crimes to the commune authorities, they responded by saying there were no such crimes, and the commune authorities told them not spread this outside the community because the perpetrators were powerful.

## Responses from the sub-national authorities: (14)

1. The cooperative communities provided information to the authorities and asked the communities not worry when they saw authorities visit the villagers and seek for more information.
2. Requested for more frequent dialogue meetings between the communities and local authorities.
3. The communities helped disseminate the information about the rights and laws in the communities.
4. Enhanced good cooperation between the communities and authorities.
5. Local authorities cooperated with the communities in order to enhance the promotion of knowledge regarding fundamental freedoms.
6. Put efforts in finding solutions in order to end discrimination against dissidents.

7. The authorities did not ban gatherings-dissemination meetings but asked the organizers to inform the local authorities to help ensure the security.
8. The request of the communities to attend the monthly meetings of the Commune/Sangkat Council is the rights and obligations of the people enshrined within the laws.
9. The commune authorities have never discriminated against dissidents, but expression of opinions must be genuine and should not hide any incitement purposes.
10. Village-commune authorities would prepare letters to invite community representatives to attend the monthly commune council meetings (after the COVID-19 ends).
11. Village-commune authorities did not restrict the rights and freedoms of assembly and expression because it is a citizen's right, but they had internal fear.
12. The commune authorities would advise the village chiefs, but the youth groups must, in advance, inform the village chiefs clearly about the purpose of specific activities.
13. Because those activities were conducted without providing any prior notice to the authorities and it was during the COVID-19.
14. When the commune authorities and the officers from the administrative police posts asked them questions and took pictures of their activities, this was not a restriction or a threat to any rights or freedoms. In fact, this is not against the laws. If their activities complied with the laws, then they should not fear about being asked or taken pictures.

## Suggestions (Recommendations) from the communities: (26)

1. Suggest that the authorities hold regular meetings with the communities to resolve various issues.
2. Suggest that the Ministry of Interior raise awareness and strengthen the capacity among local officials regarding the national laws, international laws, letters of notifications and other relevant provisions.
3. Suggest that the government issue instructions to local authorities to give better access for the citizens to attend public meetings with commune councils.
4. Suggest that the Ministry of Interior instruct the provincial authorities to give citizens the right to submit petitions and other complaints without prohibition and obstruction.
5. The Forestry Administration should help accelerate the establishment of community forests in Anchanh Roung and Pich Changva communes, Kampong Chhnang province and in Choam Ksan district, Chhep district and Tbeng Meanchey district of Preah Vihear province.
6. National and sub-national authorities must ensure that people have the right to express themselves without fear with an aim to develop the communities.
7. The authorities should have good cooperation with the people to find solutions, support and encourage all interventions.
8. Village-commune authorities should not restrict but respect fundamental rights and freedoms, especially freedom of expression and assembly - for those who they consider to have the opposite views.
9. The authorities should be more open-minded and give opportunities for community representatives to attend monthly commune council meetings, and should not wait until after the end of Covid pandemic.
10. The authorities should maintain confidentiality, personal security and safety of those who reported them any suspected crimes.
11. The authorities should be neutral and impartial, should not discriminate against political tendency and stop smearing.

12. Suggest that the authorities listen to the opposite views and take the views into consideration without classifying them as the opposition groups.
13. The Ministry of Interior should issue a directive to local authorities, advising them to stop monitoring, interrogating, photographing, requesting a list of community activities and requiring the community members to report them before and after participating in activities with civil society organizations.
14. The National Authority for Land Dispute Solutions, Apsara Authority, and Ministry of Land Management should promote community participation in resolving housing issues.
15. The Ministry of Interior should issue notice to local authorities regarding freedom of political participation and political campaign during elections.
16. Commune authorities must abide by the laws and instructions from the Ministry of Interior regarding the activities of civil society organizations.
17. Provincial authorities should deal with local authorities regarding their perceived threats against community representatives who expressed their views.
18. The Ministry of Interior should increase additional commune budgets to assist community fisheries in maintaining and conserving natural resources.
19. At Commune/Sangkat Council meetings, the authorities should provide opportunities for the community to include problems of the communities in the meeting agendas.
20. The Ministry of Interior should instruct local authorities to understand the so-called defamation, agitation and incitement before filing lawsuits against those who post comments on Facebook about land disputes and forest issues.
21. The authorities should work with the communities to protect and conserve the natural resources.
22. Commune/Sangkat authorities should widely disseminate information regarding the commune/sangkat's budget, revenue, expenses.
23. The Ministry of Justice should set up offices which assist the people in writing the complaints and provide legal counselling for the local communities.
24. The authorities should notify, disseminate and encourage communities' engagement in designing development or investment plans.

25. Environment officials must recognize the involvement of the Forest Defenders Network and grant better access for the network to participate in monitoring and protecting community forests.
26. Authorities must pay attention to all reported crimes and take preventive interventions in a timely and responsible manner.

-End-

# សង្ខេបលទ្ធផល

ដើម្បីចូលរួមលើកកម្ពស់សេរីភាពមូលដ្ឋាន តាមរយៈមូលនិធិ ពង្រឹងអំណាចលទ្ធិប្រជាធិបតេយ្យ របស់អង្គការសហប្រជាជាតិ(UNDEF) គម្រោង "ពង្រឹងសមត្ថភាពមូលដ្ឋាន ដើម្បីកែលម្អគោលនយោបាយ ក្នុងប្រទេសកម្ពុជា" បានអនុវត្តសកម្មភាពនៅក្នុងខេត្តគោលដៅចំនួន៨ស្ថិតនៅក្នុង១៨ស្រុក ៣៥ឃុំ និង២៥២ភូមិគឺៈ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តព្រះវិហារ ខេត្តរតនៈគីរី ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបងមណ្ឌលគីរី និងខេត្តកំពង់ឆ្នាំង ដោយមានសកម្មភាពធំៗៈ បើកវគ្គបណ្តុះបណ្តាលអំពីសេរីភាពជាមូលដ្ឋានការតស៊ូមតិ និងការចងបណ្តាញ កិច្ចប្រជុំជាមួយអាជ្ញាធរឃុំ/សង្កាត់ និងអាជ្ញាធរខេត្ត សិក្ខាសាលាថ្នាក់តំបន់ និងសិក្ខាសាលាថ្នាក់ជាតិ។ ឆ្លងតាមការអនុវត្តន៍ សកម្មភាពជាបន្តបន្ទាប់ រហូតដល់សិក្ខាសាលាថ្នាក់ជាតិគម្រោងបានរកឃើញរបកគំហើញមួយចំនួនដូចខាងក្រោម ដើម្បីដាក់ជូន ក្រសួងនិងស្ថាប័នពាក់ព័ន្ធពិនិត្យរកដំណោះស្រាយដាក់លាក់ប្រកបដោយសន្តិភាពសុខដុមរម្យនាសំរាប់ប្រជាពលរដ្ឋក្នុងសហគមន៍ៈ

- បញ្ហាប្រឈមរបស់សហគមន៍ ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានចំនួន១៧ចំណុច ការឆ្លើយតបរបស់អាជ្ញាធរថ្នាក់ក្រោមជាតិចំនួន១៤ចំណុច និងសំណូមពរ(អនុសាសន៍)របស់សហគមន៍ចំនួន២៦ចំណុច។
- ឯកឧត្តម កត្តា អន គណម្មាធិការសិទ្ធិមនុស្សកម្ពុជា សន្យាថា នឹងលើកយកបញ្ហាប្រឈម១៧ចំណុចនិងអនុសាសន៍(សំណូមពរ)២៦ចំណុច ដាក់ចូលក្នុងរបៀបវរៈប្រជុំអន្តរក្រសួង នៃគណកម្មធិការសិទ្ធិមនុស្សកម្ពុជា ដែលមានសមាសភាព២០ក្រសួងពាក់ព័ន្ធ។ ជាពិសេស ឯកឧត្តម នឹងរៀបចំកិច្ចប្រជុំជាមួយក្រសួងពាក់ព័ន្ធទាំង៦ ដើម្បីពិនិត្យលទ្ធភាពដោះស្រាយជូនប្រជាពលរដ្ឋ។ ក្រសួង/ស្ថាប័នពាក់ព័ន្ធទាំងប្រាំមួយគឺៈ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសូងដែនដី នគររូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន ក្រសូងកសិកម្ម (រដ្ឋបាលព្រៃឈើ) និងអាជ្ញាធរអប្សារា។
- តំណាងអង្គការសង្គមស៊ីវិលទាំងពីរ លោកនាយកគ្រប់គ្រងកិច្ចការទូទៅអង្គការលីកាដូ និងលោកស្រីនាយការមេជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានឯកភាពទាំងស្រុងចំពោះរបកគំហើញបញ្ហាប្រឈម និងអនុសាសន៍ទាក់ទងនិងសេរីភាពមូលដ្ឋាន របស់សមាគមអាដហុក។
- សំណូមពរ គណកម្មាធិការសិទ្ធិមនុស្សកម្ពុជា ជួយធ្វើយ៉ាងណាលុបអត្ថន័យមួយចំនួនក្នុងសៀវភៅ-ស របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានចែងអំពីអង្គការសង្គមស៊ីវិលមួយចំនួន ពាក់ព័ន្ធបដិវត្តពណ៌.......ចំណុចនេះហើយ ដែលនាំឲ្យអាជ្ញាធរមូលដ្ឋានរឹតបន្តឹង និងឃ្លាំមើលគ្រប់សកម្មភាព ជាពិសេសអង្គការដែលមានឈ្មោះក្នុងសៀវភៅ-ស។
- តាមរយៈការចូលរួមសកម្មភាពប្រជុំពិភាក្សា ចាប់តាំងពីថ្នាក់ឃុំ/សង្កាត់ដល់ថ្នាក់ខេត្ត អាជ្ញាធរមូលដ្ឋានហាក់ដូចជា បានទទួលស្គាល់រួចហើយនូវសកម្មភាពរបស់ខ្លួន ចំពោះរបកគំហើញបញ្ហាប្រឈមរបស់សហគមន៍ទាំង១៧ចំណុច។ "ប្រធានសមាគមអាហុកបានបញ្ជាក់"។

***ទំនាក់ទំនងព័ត៌មានបន្ថែមៈ***

*១. លោក **មាស សារ៉ាត** អគ្គលេខាធិការ សមាគមអាដហុ ០៨៦ ៣៨៥៦៦៦*

*២. លោក **សឹងសែនករុណា** អ្នកនាំពាក្យ និងជាអនុប្រធានផ្នែកសិទ្ធិមនុស្ស និងដីធ្លី ០៨៦ ៣២៤៦៦៦*

# របាយការណ៍

## ១. សេចក្តីផ្តើម

សមាគមអាដហុកគឺជាអង្គការសិទ្ធិមនុស្សកម្ពុជាដំបូងគេដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី១០ខែធ្នូ ឆ្នាំ១៩៩១ ដើម្បីធ្វើការតស៊ូមតិលើកកម្ពស់សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ និងទទួលស្គាល់ជាផ្លូវការដោយ សម្តេចព្រះ នរោត្តម សីហនុ ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩២ ព្រមទាំងចុះបញ្ជីក្រសួងមហាផ្ទៃ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០០ប្រកាសលេខ២៧៨។ សមាគមអាដហុក បាននឹងកំពុងធ្វើប្រតិបត្តិការសកម្មភាពសំខាន់ៗដូចជា៖ ការពង្រឹងសិទ្ធិអំណាចសហគមន៍មូលដ្ឋាន ការតស៊ូមតិ និងការឃ្លាំមើល និងអន្តរាគមន៍ពាក់ព័ន្ធការរំលោភសិទ្ធិមនុស្ស ដីធ្លី រួមទាំងសិទ្ធិស្ត្រី កុមារជាដើម។

គម្រោង "ពង្រឹងសមត្ថភាពមូលដ្ឋានដើម្បីកែលម្អគោលនយោបាយក្នុងប្រទេសកម្ពុជា"មានគោលបំណងលើកកម្ពស់សិទ្ធិចូលរួមរបស់សហគមន៍មូលដ្ឋាន ក្នុងការពិភាក្សាជាសាធារណៈតាមរយៈការអភិវឌ្ឍន៍និងការពង្រឹងចំណេះដឹងសិទ្ធិមនុស្ស សេរីភាពមូលដ្ឋាន ការកសាងបណ្តាញ ជំនាញតស៊ូមតិនិងអាចបញ្ជូនសម្លេងរបស់ពួកគាត់ដើម្បីស្តារឡើងវិញនូវវប្បធម៌សន្ទនា រវាងសហគមន៍មូលដ្ឋាន និងអង្គភាពរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងដើម្បីចូលរួមចំណែក ក្នុងការកែលម្អគោលនយោបាយដើម្បីជានាការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ក្នុងប្រទេសកម្ពុជា។

## ទិដ្ឋភាពគម្រោង




**ប្រភពបញ្ហា៖** នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គឺបន្ទាប់ពីការបោះឆ្នោតជាតិឆ្នាំ២០១៣ មកការថយចុះនៃការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានត្រូវបានគេមើលឃើញថា ធ្វើឲ្យមានការប៉ះពាល់យ៉ាងខ្លាំង

ដល់ដំណើរការលទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ។ របាយការណ៍ស្តីពីសេរីភាពឆ្នាំ២០១៩ របស់អង្គការ Freedom House បានចាត់ថ្នាក់ប្រទេសកម្ពុជាជាប្រទេស "មិនសេរី" ហើយបាត់បង់ ៤ពិន្ទុចន្លោះឆ្នាំ ២០១៧ និង ២០១៨ ដែលបង្ហាញឲ្យឃើញពីការធ្លាក់ចុះដ៏សំខាន់បំផុតមួយនៅទូទាំងពិភពលោក។

ការរឹតត្បិតលើសង្គមស៊ីវិល និងសេរីភាពជាមូលដ្ឋាន គឺជាកត្តាបង្កឲ្យមានភាពរាំងស្ទះដល់ប្រទេសកម្ពុជាក្នុងការរីកចម្រើន ជាពិសេសសហគមន៍ក្រីក្រ និងជនពិការដែលរស់នៅតំបន់ដាច់ស្រយាល មានចំណេះដឹងតិចតួចអំពីសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់ពួកគេ ដែលរារាំងសមត្ថភាពរបស់ពួកគេក្នុងការចូលរួមក្នុងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ ហើយពួកគេក្លាយទៅជាជនងាយរងគ្រោះខ្លាំងចំពោះការរំលោភសិទ្ធិ។ កត្តាទាំងនេះ មានភាពប្រទាំងប្រទើសជាមួយ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិត្រង់ **ទិសដៅ១៦.៧** "ធានាឱ្យមានការឆ្លើយតប រួមបញ្ចូល ការចូលរួម និងការសម្រេចចិត្តជាតំណាងនៅគ្រប់កម្រិតទាំងអស់" **ទិសដៅ១៦.១០** " ធានាការចូលប្រើប្រាស់ជាសាធារណៈនូវព័ត៌មាន និងការពារសេរីភាពជាមូលដ្ឋានស្របតាមច្បាប់ជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិ" **គោលដៅទី១** "បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់" **គោលដៅទី៥** "សម្រេចបានសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងកុមារីទាំងអស់" សមាគមអាដហុកបានរកឃើញបញ្ហាសំខាន់ៗបីដូចខាងក្រោម៖

- **បញ្ហាទី១៖** កង្វះចំណេះវិជ្ជាជំនាញផ្នែកតស៊ូមតិ និងការចងក្រងបណ្តាញសហគមន៍មូលដ្ឋាន
- **បញ្ហាទី២៖** ទំនាក់ទំនង-ការផ្តល់ទទួលព័ត៌មាន រវាងសហគមន៍មូលដ្ឋាន ក្នុងការបង្ហាញអំពី កង្វល់ បញ្ហាប្រឈម និងអនុសាសន៍ ជាមួយមន្ត្រីអាជ្ញាធរមូលដ្ឋាន ខេត្ត និងថ្នាក់ជាតិ នៅមានភាពមិនច្បាស់លាស់។
- **បញ្ហាទី៣៖** លំហរវប្បធម៌សន្ទនា រវាងសមាជិកសហគមន៍មូលដ្ឋាន ដើម្បីចែករំលែក កង្វល់បញ្ហាប្រឈម និងអនុសាសន៍ ជាមួយអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋាន នៅមានកម្រិត។

ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ ជាពិសេសសេរីភាពមូលដ្ឋាន ក្រោមជំនួយមូលនិធិពង្រឹងអំណាចលទ្ធិប្រជាធិបតេយ្យរបស់អង្គការសហប្រជាជាតិ (UNDEF) សមាគមអាដហុកបានអនុវត្តនៅខេត្តគោលដៅចំនួន៨ស្ថិតនៅក្នុង១៨ស្រុក ៣៥ឃុំ និង២៥២ភូមិគឺ៖ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តព្រះវិហារ ខេត្តរតនៈគីរី ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង មណ្ឌលគីរី និងខេត្តកំពង់ឆ្នាំង។ តាមសកម្មភាពធំៗចំនួន០៦គឺ៖ បើកវគ្គបណ្តុះបណ្តាលអំពីសេរីភាពជាមូលដ្ឋាន ការតស៊ូមតិ និងការចងបណ្តាញដល់តំណាងសហគមន៍១,២២៥នាក់ មកពី៣៥ឃុំ-សង្កាត់ផ្សេងៗគ្នា - កិច្ចប្រជុំជាមួយអាជ្ញាធរមូលដ្ឋានដែលផ្តោតសំខាន់លើសេរីភាពជាមូលដ្ឋាន - កិច្ចប្រជុំជាមួយអាជ្ញាធរខេត្ត ដែលពិភាក្សាអំពីបញ្ហាប្រឈម និងអនុសាសន៍របស់សហគមន៍ ដែលមិនទាន់មានដំណោះស្រាយច្បាស់លាស់ - សិក្ខាសាលាថ្នាក់តំបន់ ដែលបន្តពិភាក្សាជាមួយសហគមន៍អំពីបញ្ហាប្រឈម អនុសាសន៍ និងដំណោះស្រាយមិនច្បាស់លាស់របស់អាជ្ញាធរខេត្ត ដើម្បីរៀប ចំធ្វើផែនការយុទ្ធសាស្ត្រ ព្រមទាំងប្រមូលធាតុចូលសំរាប់យកមកធ្វើការពិភាក្សានៅក្នុងសិក្ខាសាលាថ្នាក់ជាតិ និងប្រជុំធ្វើបច្ចុប្បន្នភាពជាមួយអាជ្ញាធរថ្នាក់ជាតិដើម្បីបន្តពិភាក្សាអំពីរបាយការណ៍សិក្ខាសាលាថ្នាក់ជាតិ។




**១២៨ កិច្ចប្រជុំរវាងតំណាងសហគមន៍មូលដ្ឋាន** ជាមួយអាជ្ញាធរមូលដ្ឋាន ស្ថិតក្នុងឃុំ-សង្កាត់ចំនួន៣៥ នៃខេត្តគោលដៅទាំង៨។ កិច្ចប្រជុំនេះ ជាការផ្តល់ឱកាសសំរាប់ សហគមន៍ លើកយកបញ្ហាផ្សេងៗដែលបានកើតមានឡើងក្នុងមូលដ្ឋាន ជាពិសេស ការព្រួយបារម្ភណ៍បញ្ហាប្រឈម អនុសាសន៍ ទៅដល់អាជ្ញាធរមូលដ្ឋានរបស់ពួកគេផ្ទាល់ដើម្បីស្វែងរកដំណោះស្រាយជាក់លាក់។

កិច្ចប្រជុំនេះ មានអ្នកចូលរួមសរុប២០៥២នាក់ តំណាងសហគមន៍ ១,០២៨នាក់(ក្នុងនោះមានស្រ្តី៦០០នាក់-យុវជន៣៨៣នាក់-ជនជាតិដើមភាគតិច៥៥៩នាក់) ក្រុមប្រឹក្សាឃុំ-សង្កាត់ និងមេភូមិ ៤៩៥នាក់ និងនគរបាលប៉ុស្តិ៍រដ្ឋបាល ២៧៤នាក់។

តាមការវិភាគ មានបញ្ហាដែលលើកឡើងដោយសហគមន៍ត្រឹមតែ១៥%ប៉ុណ្ណោះ ដែលមានការឆ្លើយតប ដោយឡែកបញ្ហា និងអនុសាសន៍ ដែលនៅសេសសល់ជាច្រើន ត្រូវបានរៀបចំដើម្បីយកទៅពិភាក្សារកដំណោះស្រាយនៅថ្នាក់ខេត្ត។



Preaek Koy Commune, Kang Meas district, Kampong Cham Province (at Preaek Koy Commune’s Office)

**៦ កិច្ចប្រជុំជាមួយអាជ្ញាធរថ្នាក់ខេត្ត** នៃខេត្តគោលដៅទាំង៨។ កិច្ចប្រជុំនេះ អនុញ្ញាតឲ្យតំណាងសហគមន៍មានឱកាសលើកយកបញ្ហាដែលមិនទាន់មានដំណោះស្រាយនៅតំណាក់ការ ប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីបន្តពិភាក្សារកដំណោះស្រាយ។




កិច្ចប្រជុំនេះដែរ មានការចូលរួមដោយ តំណាងសហគមន៍៨៦នាក់ អភិបាលរងខេត្ត ស្នងការរងខេត្ត កង

រាជអាវុធហត្ថខេត្ត និងមន្ទីរពាក់ព័ន្ធ ចំនួន៤១នាក់ និងក្រុមប្រឹក្សាឃុំ-សង្កាត់ និងនគរបាលប៉ុស្តិ៍រដ្ឋបាល ៣១ នាក់។

តាមការវិភាគមានបញ្ហាត្រឹមតែ២០% ប៉ុណ្ណោះដែលទទួលបានការឆ្លើយតបដោយឡែកបញ្ហានិងអនុសាសន៍ ដែលនៅសល់ត្រូវបានរៀបចំធ្វើបច្ចុប្បន្នភាព ដើម្បីយកទៅពិភាក្សាបន្ថែមនៅក្នុងសិក្ខាសាលាថ្នាក់តំបន់ មុនលើកយកមកពិភាក្សាបន្តនៅថ្នាក់ជាតិ។

**តាមរបាយការណ៍៖** មូលហេតុដែលខកខានមិនបានរៀបចំកិច្ចប្រជុំជាមួយអាជ្ញាធរខេត្តទាំងពីរគឺ

- **ខេត្តព្រះវិហារ:** គណអភិបាលលខេត្តខ្វះកិច្ចសហការណ៍ ដោយព្យាយាមមិនផ្តល់ការសម្របសម្រួល បើទោះសមាគមអាដហុកបានខិតខំរៀបចំលិខិតស្នើសុំកិច្ចសហប្រតិបត្តិការ និងអញ្ជើញចូលរួម ប៉ុន្តែអស់រយៈពេលជាង២សប្តាហ៍ រដ្ឋបាលខេត្តនៅតែមិនឆ្លើយបតលិខិត ទូរស័ព្ទជាច្រើនដងមិនទទួល ទៅដល់ការិយាល័យក៏មិនបានជួបជាច្រើនដង។
- **ខេត្តបាត់ដំបង:** ដោយសារគណៈអភិបាលខេត្ត និងមន្ត្រីមួយចំនួនមានភារៈកិច្ចមមាញឹកក្នុងការចុះពង្រឹងបក្សមុនពេលយុទ្ធនាការបោះឆ្នោតឃុំ-សង្កាត់មកដល់ដូច្នោះហើយមិនមានពេលចូលរួមកិច្ចប្រជុំបាន។


រូបថត: កិច្ចប្រជុំជាមួយអាជ្ញាធរខេត្តកំពង់ចាម




**០២ សិក្ខាសាលាប្រចាំតំបន់** ដែលមានអ្នកចូលរួម ជាតំណាងសហគមន៍មូលដ្ឋានសរុបចំនួន១២៧នាក់ មកពី៣៥សហគមន៍ផ្សេងៗគ្នា នៃខេត្តគោលដៅទាំង៨។ សិក្ខាសាលាទី១ធ្វើនៅខេត្តកំពង់ចាម មានអ្នកចូលរួមចំនួន៦៥នាក់ (រួមទាំងតំណាងមកពីអង្គការសហប្រជាជាតិ) មកពីខេត្តចំនួន០៤គឺ ខេត្តរតនៈគីរី ខេត្តកំពង់ចាម ខេត្តមណ្ឌលគីរី និងខេត្តសៀមរាប និងសិក្ខាសាលាទី២ ធ្វើនៅខេត្តបន្ទាយមានជ័យ មានអ្នកចូលរួមចំនួន៦២នាក់មកពីខេត្តចំនួន០៤គឺ ខេត្តកំពង់ឆ្នាំង ខេត្តបាត់ដំបងខេត្តព្រះវិហារ និងខេត្តបន្ទាយមានជ័យ។

សិក្ខាសាលានេះ ផ្តល់ឱកាសតំណាងសហគមន៍មូលដ្ឋាន អាចចែករំលែកការព្រួយបារម្ភណ៍ បញ្ហាប្រឈម




របស់សហគមន៍ខ្លួន ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន ដល់អ្នកចូលរួម ព្រមទាំងរួមគ្នាដើម្បីផ្តល់អនុសាសន៍ដល់រដ្ឋាភិបាល បន្តស្វែងរកដំណោះស្រាយ បញ្ហាប្រឈម និងចូលរួមរៀបចំផែនការយុទ្ធសាស្ត្រតស៊ូមតិសំរាប់សិក្ខាសាលាថ្នាក់ជាតិ។



ឆ្លងតាមសកម្មភាព កិច្ចប្រជុំថ្នាក់មូលដ្ឋាន ចំនួន១២៨លើក កិច្ចប្រជុំថ្នាក់ខេត្ត០៦លើក និងសិក្ខាសាលាប្រចាំតំបន់០២លើក អាចប្រមូលបានធាតុចូល ដើម្បីដាក់ជូនសិក្ខាសាលាជាតិ ដែលមានក្រសួងពាក់ព័ន្ធចូលរួមរកដំណោះស្រាយ ជាពិសេសក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ជាដើម។ ធាតុចូលដែលប្រមូលបានក្រោយមិនមានដំណោះស្រាយច្បាស់លាស់ពីអាជ្ញាធរថ្នាក់ក្រោមជាតិដូចជា៖ បញ្ហាប្រឈមនិងអនុសាសន៍របស់សហគមន៍មូលដ្ឋាន ព្រមទាំងផែនការសកម្មភាព កំណត់ដោយសហគមន៍ ក្នុងគោលបំណងស្នើសុំឲ្យមានការផ្លាស់ប្តូរ និងយល់ព្រមពីរដ្ឋាភិបាល៖

**<u>០១ សិក្ខាសាលាថ្នាក់ជាតិ</u>**៖ មានរយៈពេល២ថ្ងៃ(២៣-២៤ ខែសីហា ឆ្នាំ២០២២)នៅសណ្ឋាគារសាន់វេ ដែលមានអ្នកចូលរួមសរុប១៤៣នាក់ (ស្រី៤៩នាក់) ក្នុងនោះ តំណាងសហគមន៍មូលដ្ឋានចំនួន១១៣នាក់អង្គការសង្គមស៊ីវិល២៤នាក់ អ្នកយកព័ត៌មានសង្គម០៥នាក់ និងតំណាងគណម្មាធិការសិទ្ធិមនុស្ស០១នាក់ (អវត្តមានតំណាងក្រសួងមហាផ្ទៃ និងតំណាងក្រសួងយុត្តិធម៌)។ សិក្ខាសាលា ទទួលបានលទ្ធផលគួឲ្យកត់សំគាល់ដូចជា៖ បញ្ហាប្រឈមរបស់សហគមន៍១៧ចំណុច ការឆ្លើយបតរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ១៤ចំណុច និងសំ

ណ្ហំពរ(អនុសាសន៍)របស់សហគមន៍២៦ចំណុច ហើយតំណាងគណម្មាធិការសិទ្ធិមនុស្ស បានសន្យានាំយក






របគំហើញទាំងនេះ ទៅដាក់បញ្ចូលក្នុងរបៀបវរៈ ប្រជុំពិភាក្សា រវាងក្រុមបច្ចេកទេសសិទ្ធិមនុស្ស ដែលមានសមាសភាពមកពីអន្តរៈក្រសួងចំនួន២០ ដើម្បីរកដំណោះស្រាយជូនប្រជាសហគមន៍។ ទន្ទឹមនេះតំណាងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងសម្ព័ន្ធខ្មែរ ជំរឿននិងការពារសិទ្ធិមនុស្សលីកាដូ បានឯកភាពទាំងស្រុង ចំពោះរបាយការណ៍របកគំហើញរបស់សមាគមអាដហុក ខណៈដែលប្រធានសមាគមអាដហុកបានសង្កត់ធ្ងន់ថាតាមរយៈការចូលរួមកិច្ចប្រជុំថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្ត អាជ្ញាធរ បានទទួលស្គាល់រួចហើយ ចំពោះបញ្ហាប្រឈម និងសំណូមពរ(អនុសាសន៍)របស់សហគមន៍មូលដ្ឋាន ព្រមទាំងបានឆ្លើយតបសហគមន៍ចំពោះបញ្ហាប្រឈមមួយចំនួនទៀតផង។

**បញ្ហាទូទៅះ** បញ្ហាពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវគមនាគមន៍នៅក្នុងសហគមន៍ បញ្ហាសុខុមាលភាព និងអនាម័យ បញ្ហាសន្តិសុខ និងសុវត្ថិភាពក្នុងភូមិ-ឃុំ បញ្ហាចំណាកស្រុក បញ្ហានេសាទខុសច្បាប់ បញ្ហាវិវាទដីធ្លីដោយអ្នកមានអំណាច-មានប្រាក់ និងការរានព្រៃអភិរក្សដោយខុសច្បាប់ ការបិទទឹកអាងត្រពាំងថ្មនាំឲ្យប៉ះពាល់ដល់ការធ្វើស្រែរបស់ប្រជាពលរដ្ឋនៅជុំវិញនោះ បញ្ហាហឹង្សាក្នុងគ្រួសារ បញ្ហាសេដ្ឋកិច្ចប្រជាពលរដ្ឋធ្លាក់ចុះ-ក្រីក្រ-ជំពាក់ធនាគារមិនមានប្រាក់សង។

## បញ្ហាប្រឈមពាក់ព័ន្ធសេរីភាពមូលដ្ឋានៈ (១៧)

1. អាជ្ញាធរមូលដ្ឋានកន្លែងខ្លះតែងតែ ឃ្លាំមើល តាមដាន និងសួរនាំ ហើយតម្រូវឲ្យសហគមន៍រាយការណ៍នៅពេលត្រឡប់ពីចូលរួមអង្គប្រជុំ ឬសិក្ខាសាលាជាមួយអង្គការសង្គមស៊ីវិល។
2. អាជ្ញាធរគំរាមថាប្រយ័ត្នជាប់គុក! បើចូលរួមប្រជុំ ឬវគ្គជាមួយអង្គការត្រូវតែរាយការណ៍ឲ្យអាជ្ញាធរពេលចេញទៅចូលរួមប្រជុំ ពាក់ព័ន្ធការដាក់ពាក្យបណ្តឹងតវ៉ាករណីដីធ្លី។
3. អាជ្ញាធរកន្លែងខ្លះ ចាត់ទុកថាជាក្រុមប្រឆាំង ចំពោះសហគមន៍ណា ដែលហ៊ានរិះគន់ដើម្បីស្ថាបនា លើភាព អសកម្មនៃការផ្តល់សេវាសាធារណៈឬនិយាយពីបញ្ហាអំពើពុករលួយជាដើម។
4. អាជ្ញាធរមូលដ្ឋានរឹតត្បិតសហគមន៍មិនឲ្យនិយាយ ឬប្តឹងតវ៉ារឿងបញ្ហាដីធ្លី-បញ្ហាព្រៃឈើ។
5. អាជ្ញាធររារាំង មិនឲ្យសហគមន៍ឡើងទៅដាក់ញ្ញត្តិនៅសាលាខេត្ត ឬនៅក្រសួង។
6. អាជ្ញាធរ មិនបានរក្សាភាពសម្ងាត់ ចំពោះការរាយការណ៍ របស់សហគមន៍អំពីបទល្មើសផ្សេងៗនាំឲ្យប៉ះពាល់ដល់សន្តិសុខសុវត្ថិភាពផ្ទាល់ខ្លួនលែងហ៊ានរាយការណ៍។
7. ការបញ្ចេញមតិពាក់ព័ន្ធរឿងនយោបាយត្រូវបានរឹតត្បឹត និងបំភិតបំភ័យ ពីសំណាក់អាជ្ញាធរ។
8. អាជ្ញាធរមិនផ្តល់ឱកាសដល់អ្នកដែលមានទស្សនៈផ្ទុយបានចូលរួមម។
9. ក្រុមប្រឹក្សាឃុំមិនទាន់ផ្តល់កិច្ចសហការក្នុងការអនុញ្ញាតសហគមន៍បានចូលរួមកិច្ចប្រជុំប្រចាំខែ។
10. អាជ្ញាធរ មានការរឹតត្បឹត រើសអើងសហគមន៍ ក្នុងការចូលរួមសកម្មភាពការងារជាមួយសង្គមស៊ីវិល និងសកម្មភាពនយោបាយ (ដូចជា៖ តាមឃ្លាំមើល-សួរនាំ-ថតរូប-គំរាមកំហែង) ដោយចោទប្រកាន់-លាបពណ៌ថាមាននិន្នាការគណបក្សនយោបាយ។
11. អាជ្ញាធរភូមិ រារាំងរឹតត្បឹត យុវជនក្នុងការចូលរួមសកម្មភាពសង្គមផ្សេងៗ ដូចជាការជួសជុលផ្លូវ ការចែករំលែកចំណេះដឹងអំពីសិទ្ធិ អំពីតួនាទីពលរដ្ឋ។
12. អាជ្ញាធរសមត្ថកិច្ចរឹតត្បឹតសកម្មជួបជុំរបស់អង្គការសង្គមស៊ីវិល និងសហគមន៍ នៅតាមមូលដ្ឋាន តម្រូវឲ្យជូនដំណឹង សុំការអនុញ្ញាតិ ទាមទារលិខិតស្នាម-ឯកសារផ្សេងៗ ថតរូប អង្គុយស្តាប់ ព្រមទាំងប្រាប់ទីតាំងបញ្ជូនរូបថតសកម្មភាពឱ្យអាជ្ញាធរផង។
13. ប្រជាពលរដ្ឋមានការភ័យខ្លាចក្នុងការបង្ហោះសារបញ្ចេញមតិពាក់ព័ន្ធរឿងនយោបាយ។
14. អាជ្ញាធរអប្បរា មិនបានផ្តល់ដំណោះស្រាយសមរម្យ ចំពោះមតិស្នើសុំរបស់ប្រជាសហគមន៍ពាក់ព័ន្ធករណីសិទ្ធិមានលំនៅដ្ឋាន។
15. ផ្ជាធរឃុំគម្រាម និងកោះហៅទៅសួរនាំ ដោយគ្រាន់តែតំណាងសហគមន៍លើកបញ្ហាដីធ្លីក្នុងកិច្ចប្រជុំ ។
16. មន្ត្រីបរិស្ថានមិនអនុញ្ញាតឲ្យប្រជាសហគមន៍ចូលរួមឃ្លាំមើល និងការពារទ្រព្យសម្បត្តិសាធារណៈ ដូចជានៅខេត្តព្រះវិហារ ខេត្តមណ្ឌលគីរី ខេត្តរតនគីរី ខេត្តសៀមរាប។
17. ប្រជាពលរដ្ឋឃើញបទល្មើសព្រៃឈើទៅរាយការណ៍ អាជ្ញាធរឃុំថាគ្មានបទល្មើសនឹងទេ ហើយអាជ្ញាធរឃុំប្រាប់ថាកុំនិយាយចេញក្រៅ ព្រោះអ្នកប្រព្រឹត្តជាអ្នកមានអំណាច។

## ការឆ្លើយតបរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ៖ (១៤)

1. សហគមន៍សហការណ៍ផ្តល់ព័ត៌មានដល់អាជ្ញាធរ និងសមត្ថកិច្ច ហើយសូមកុំព្រួយបារម្ភណ៍ពេលឃើញសមត្ថកិច្ចចុះទៅសួរសុខទុក្ខ និងសួរព័ត៌មានតាមភូមិ។
2. សូមរៀបចំឲ្យមានកិច្ចប្រជុំសន្ទនាគ្នារវាងសហគមន៍ និងអាជ្ញាធរមូលដ្ឋានឲ្យបានញឹកញាប់។
3. សហគមន៍ជួយផ្សព្វផ្សាយពីសិទ្ធិអំណាច និងច្បាប់ដល់ពលរដ្ឋ។
4. ពង្រឹងកិច្ចសហការណ៍គ្នាល្អរវាងអាជ្ញាធរ និងសហគមន៍។
5. អាជ្ញាធរមូលដ្ឋាន សហការណ៍ជាមួយសហគមន៍ ដើម្បីជួយជម្រុញការផ្សព្វផ្សាយចំណេះដឹងពាក់ព័ន្ធសេរីភាពមូលដ្ឋាន។
6. ប្រឹងប្រែងរកដំណោះស្រាយយ៉ាងណាដើម្បីលុបបំបាត់ការរើសអើងចំពោះអ្នកមានមតិផ្ទុយ។
7. អាជ្ញាធរមិនហាមឃាត់សកម្មភាពប្រជុំ-ផ្សព្វផ្សាយអ្វីទេ តែសូមអ្នករៀបចំកម្មវិធី ជូនដំណឹងអាជ្ញាធរមូលដ្ឋានដើម្បីការការពារសន្តិសុខ។
8. ការស្នើសុំរបស់សហគមន៍ ចូលរួមកិច្ចប្រជុំប្រចាំខែក្រុមប្រឹក្សាឃុំ/សង្កាត់ជាសិទ្ធិ និងកាតព្វកិច្ចដែលមានចែងក្នុងច្បាប់។
9. អាជ្ញាធរឃុំ មិនដែលមានការរើសអើងចំពោះអ្នកមានទស្សនៈផ្ទុយទេ ប៉ុន្តែការបញ្ចេញមតិត្រូវតែមានភាពពិតប្រាកដ និងគ្មានបង្កប់ភាពញុះញង់។
10. អាជ្ញាធរភូមិ-ឃុំ នឹងរៀបចំធ្វើលិខិតអញ្ជើញ តំណាងសហគមន៍ចូលរួមប្រជុំក្រុមប្រឹក្សាឃុំប្រចាំខែ (ពេលចប់កូវីត១៩)។
11. អាជ្ញាធរភូមិ-ឃុំ មិនបាន ហាមឃាត់ រឹតត្បឹត សិទ្ធិសេរីភាពជួបជុំ និងសិទ្ធិបញ្ចេញមតិទេ ព្រោះជាសិទ្ធិប្រជាពលរដ្ឋ ប៉ុន្តែពួកគេខ្លាចដោយខ្លួនឯង។
12. អាជ្ញាធរឃុំនឹងធ្វើការណែនាំមេភូមិ ប៉ុន្តែក្រុមយុវជន ត្រូវផ្តល់/ប្រាប់មេភូមិ ឲ្យច្បាស់អំពីគោលបំណងនៃសកម្មភាពជាក់លាក់ជាមុន។
13. ដោយសារការធ្វើសកម្មភាពនោះមិនបានជូនដំណឹងអាជ្ញាធរជាមុន និងធ្វើក្នុងអំឡុងពេលកូវីដ១៩។
14. គ្រាន់តែអាជ្ញាធរឃុំ និងប៉ូលីសប៉ុស្តិ៍ចុះទៅសួរនាំ ហើយថតរូបសកម្មភាព ដែលកំពុងធ្វើគឺមិនមែនជាការរឹតត្បឹត ឬក៏គំរាមកំហែងសិទ្ធិសេរីភាពអ្វី តាមពិតមិនខុសច្បាប់អ្វីទេ បើសកម្មភាពនោះត្រូវច្បាប់ខ្លាចអ្វីគ្រាន់គេសួរនាំ-ថតរូប។

## សំណូមពរ(អនុសាសន៍)របស់សហគមន៍៖ (២៦)

1. សំណូមពរឲ្យអាជ្ញាធររៀបចំកិច្ចប្រជុំជាមួយសហគមន៍ជាទៀងទាត់ដើម្បីដោះស្រាយបញ្ហាផ្សេងៗ។
2. សូមក្រសួងមហាផ្ទៃធ្វើការផ្សព្វផ្សាយ ពង្រឹងសមត្ថភាព មន្ត្រីមូលដ្ឋាន យល់ដឹងអំពីច្បាប់ជាតិ ច្បាប់អន្តរជាតិ ស.ជ.ណ និងបញ្ញាតិពាក់ព័ន្ធនានា។
3. ស្នើសុំរដ្ឋាភិបាលចេញសេចក្តីណែនាំ ដល់អាជ្ញាធរមូលដ្ឋាន បើកទូលាយដល់ពលរដ្ឋបានចូលរួមប្រជុំជាសាធារណជាមួយក្រុមប្រឹក្សាឃុំសង្កាត់។
4. ក្រសួងមហាផ្ទៃណែនាំអាជ្ញាធរខេត្ត ផ្តល់សិទ្ធិឲ្យប្រជាពលរដ្ឋដាក់ញ្ញាតិ និងពាក្យបណ្តឹងផ្សេងៗ ដោយគ្មានការហាមឃាត់ និងរារាំង។
5. សូមរដ្ឋបាលព្រៃឈើ ជួយពន្លឿនការបង្កើតសហគមន៍ព្រៃឈើ នៅឃុំអញ្ចាញរូង និងឃុំពេជ្រចង្វា ខេត្តកំពង់ឆ្នាំង និង ស្រុកជាំក្សាន្ត ស្រុកឆែប និងស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។
6. អាជ្ញាធរថ្នាក់ជាតិ និងក្រោមជាតិ ត្រូវធ្វើយ៉ាងណាដើម្បីធានាថា ប្រជាពលរដ្ឋមានសិទ្ធិក្នុងការបញ្ចេញមតិដោយគ្មានការភ័យខ្លាចក្នុងគោលដៅអភិវឌ្ឍន៍សហគមន៍។
7. សូមឲ្យអាជ្ញាធរមានកិច្ច សហការណ៍ល្អជាមួយប្រជាពលរដ្ឋ ជួយរកដំណោះស្រាយ ជួយគាំទ្រលើកទឹកចិត្តរាល់កិច្ចអន្តរាគមន៍។
8. អាជ្ញាធរភូមិ-ឃុំ កុំមានការរឹតត្បឹត គោរពសិទ្ធិសេរីភាពមូលដ្ឋាន ជាពិសេសសេរីភាពបញ្ចេញមតិ និងសេរីភាពជួបជុំ - ចំពោះអ្នកដែលគិតថាមានទស្សនៈផ្ទុយ។
9. អាជ្ញាធរបើកចិត្តទូលាយ-ផ្តល់ឱកាស តំណាងសហគមន៍បានចូលរួមប្រជុំក្រុមប្រឹក្សាឃុំប្រចាំខែ - កុំរង់ចាំរហូតដល់ពេលចប់កូវិដ។
10. អាជ្ញាធររក្សាការសម្ងាត់ សន្តិសុខ-សុវត្ថិភាព ផ្ទាល់ខ្លួនអ្នករាយការណ៍ព័ត៌មានបទល្មើស។
11. អាជ្ញាធរមានអព្យាក្រឹត្យភាពមិនលំអៀង-មិនប្រកាន់និន្នាការនយោបាយ និងបញ្ឈប់ការលោបពណ៌គ្នា។
12. សូមឲ្យអាជ្ញាធរស្តាប់មតិផ្ទុយ ហើយធ្វើការពិចារណា ដោយកុំចាត់ទុកជាក្រុមប្រឆាំង។
13. ក្រសួងមហាផ្ទៃ ចេញសេចក្តីណែនាំអាជ្ញាធរមូលដ្ឋានឈប់ឃ្លាំមើល តាមដាន សួរនាំ-ថតរូប សុំបញ្ជីវត្តមាននូវសកម្មភាពការងារសហគមន៍ និងតម្រូវឲ្យសហគមន៍រាយការណ៍ពេលមុនទៅចូលរួមនិងត្រឡប់ពីចូល រួមសកម្មភាពជាមួយអង្គការសង្គមស៊ីវិលវិញ។
14. អាជ្ញាធរជាតិដោះស្រាយបញ្ហាដីធ្លី អាជ្ញាធរអប្សរា ក្រសួងដែនដី ជម្រុញ ការចូលរួមរកដំណោះស្រាយករណីលំនៅដ្ឋានរបស់ប្រជាសហគមន៍។
15. ក្រសួងមហាផ្ទៃចេញសេចក្តីណែនាំអាជ្ញាធរមូលដ្ឋាន អំពីសេរីភាពចូលរួមនយោបាយ និងការឃោសនានយោបាយក្នុងការបោះឆ្នោត។
16. អាជ្ញាធរឃុំត្រូវគោរពច្បាប់-សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃពាក់ព័ន្ធសកម្មរបស់អង្គការសង្គមស៊ីវិល។
17. អាជ្ញាធរខេត្តណែនាំអាជ្ញាធរមូលដ្ឋាន ពាក់ព័ន្ធការគម្រាមតំណាងសហគមន៍ក្នុងការបញ្ចេញមតិ។

18. ក្រសួងមហាផ្ទៃគួរតែបញ្ចូលបន្ថែម កញ្ចប់ថវិកាឃុំ-សង្កាត់ ជួយដល់សហគមន៍ នេសាទ ព្រៃឈើក្នុងការថែរក្សានិងអភិរក្សធនធានធម្មជាតិ។
19. នៅពេលប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ អាជ្ញាធរ គួរតែផ្តល់ឪកាសឲ្យសហគមន៍លើកបញ្ហារបស់សហគមន៍ដាក់បញ្ចូលទៅក្នុងរបៀបវារៈប្រជុំ។
20. ក្រសួងមហាផ្ទៃ ធ្វើការណែនាំអាជ្ញាធរមូលដ្ឋាន ឲ្យយល់អំពីអ្វីដែលហៅថាបរិហា បំពុលសង្គម ញុះញង់ មុនធ្វើការចោទប្រកាន់ទៅលើប្រជាពលរដ្ឋ ដែលបញ្ចេញមតិបង្ហោះតាមបណ្តាញសង្គម Facebook និយាយអំពីបញ្ហាដីធ្លី និងព្រៃឈើ ។
21. អាជ្ញាធរគួរតែ ជួយទប់ស្កាត់ ជាមួយសហគមន៍ក្នុងការការពារអភិរក្សធនធានធម្មជាតិ
22. អាជ្ញាធរ ឃុំ-សង្កាត់ គួរធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីថវិកា ចំណូលចំណាយថវិកាឃុំ-សង្កាត់
23. ក្រសួងយុត្តិធម៌ បង្កើតការិយាល័យជួយសរសេរពាក្យបណ្តឹង និងប្រឹក្សាយោបល់នៅតាមមូលដ្ឋាន
24. អាជ្ញាធរជូនដំណឹង ផ្សព្វផ្សាយ ចូលរួម ពាក់ព័ន្ធនឹងផែនការការអភិវឌ្ឍន៍ ឬវិនិយោគ
25. មន្ត្រីបរិស្ថានត្រូវទទួលស្គាល់ការចូលរួមរបស់បណ្តាញអ្នកការពារព្រៃឈើ និងបើកសិទ្ធិឲ្យទូលាយដើម្បីឱ្យបណ្តាញចូលរួមឃ្លាំមើល និងការពារព្រៃសហគមន៍។
26. អាជ្ញាធរត្រូវយកចិត្តទុកដាក់រាល់ការរាយការណ៍ពីបទល្មើស និងអន្តរាគមន៍ទប់ស្កាត់ឱ្យទាន់ពេលវេលា និងមានទំនួលខុសត្រូវ។

-ចប់-